ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តឧត្តរមានជ័យ**
សំណុំរឿងព្រហ្មទណ្ឌលេខ ១៩១
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌលេខ ២៤(ក)
ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តឧត្តរមានជ័យ**

បានបើកសវនាការជាសាធារណៈនៅសាលជម្រះក្តីនាថ្ងៃទីម្ភៃបី ខែមិថុនា ឆ្នាំពីរពាន់ម្ភៃ វេលាម៉ោងដប់ប្រាំនិងសាមសិបនាទី លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៩១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជំម្រះ**

លោក [redacted] ប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញាអមសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

**ដើម្បីជំនុំជម្រះលើៈ**

**ឈ្មោះ** [redacted] វិបុល អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ អ្នកបើកបរឡានក្រុងអ៊ីខុង ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ចាម កាន់សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពង់ចាម នៅលីវ ឪពុកឈ្មោះ [redacted] ថុល (ស) ម្តាយឈ្មោះ [redacted] ណាយ (រ) ទោសពីមុនគ្មាន។

ជាប់ចោទពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឱ្យមានរបួសដល់អ្នកដទៃ និងបណ្តាលឱ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅកំណាត់ ផ្លូវលេខ ៦៧B ចន្លោះបង្គោលគីឡូម៉ែត្រលេខ៩៦-៩៧ ស្ថិតនៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

**មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីលោក** [redacted] និង លោកណង់ [redacted] មានការិយាល័យនៅផ្ទះលេខM03 ផ្លូវជាតិលេខ២០២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ការពារ សិទ្ធិឱ្យជនរងគ្រោះឈ្មោះ [redacted] ប៊ុនវណ្ណៈ និងឈ្មោះ [redacted] ពុទ្ធារី។

**អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ** [redacted] ថេត ហៅក្រៅ តាឥណ្ឌា ភេទប្រុស អាយុ ៣០ឆ្នាំ ទីកន្លែងកំណើតនៅភូមិជ្រលង សង្កាត់ទឹកល្អក់ ខណ្ឌព្រែទប់ ខេត្តកំពង់សោម ទីលំនៅបច្ចុប្បន្ននៅ



Scanned with CamScanner

សង្កាត់មិត្តភាព ខណ្ឌប្រាំពីរមករា រាជធានីភ្នំពេញ មុខរបរ ម្ចាស់ក្រុមហ៊ុនដឹកអ្នកដំណើរ ស៊ុនអ៊ី ប្រពន្ធឈ្មោះ [redacted] បាយ មានកូនចំនួន ០២នាក់ ឪពុកឈ្មោះ [redacted] គាន (ស) ម្ដាយឈ្មោះ [redacted] ញឹម (រ) ទោសពីមុនគ្មាន។

**ដើមបណ្ដឹងរដ្ឋប្បវេណីរួមមាន៖**

-ឈ្មោះ [redacted] ណារិទ្ធ ត្រូវជាឪពុករបស់ជនរងគ្រោះឈ្មោះ [redacted] សារ័ត្ន។

-ឈ្មោះ [redacted] សុភា ត្រូវជាម្ដាយមីងរបស់ជនរងគ្រោះឈ្មោះ [redacted] វណ្ណៈ។

-ឈ្មោះ [redacted] រីន ត្រូវជាបងបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] រដ្ឋា។

-ឈ្មោះ [redacted] ដេត ត្រូវជាកូនប្រសារជនរងគ្រោះឈ្មោះ [redacted] កន។

-ឈ្មោះ [redacted] បំណាង ត្រូវជាតំណាងឱ្យជនរងគ្រោះឈ្មោះ [redacted] យួន។

-ឈ្មោះ [redacted] សុផល ត្រូវជាតំណាងឱ្យជនរងគ្រោះឈ្មោះ [redacted] ដាន។

**បានឃើញ**

-កំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមលេខ ០០២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ។

**នាពេលសវនាការ**

លោកចៅក្រមជំនុំជម្រះបានប្រាប់ទៅជនជាប់ចោទថា លោកតំណាងអយ្យការចោទប្រកាន់ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរព កាតព្វកិច្ចបណ្ដាលឱ្យមានរបួសដល់អ្នកដទៃ និងបណ្ដាលឱ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅកំណាត់ ផ្លូវលេខ ៦៧B ចន្លោះបង្គោលគីឡូម៉ែត្រលេខ៩៦-៩៧ ស្ថិតនៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនវណ្ណៈ ៖ ខ្ញុំឈ្មោះ [redacted] ប៊ុនវណ្ណៈ ត្រូវជាជនរងគ្រោះក្នុងករណីគ្រោះថ្នាក់ចរាចរណ៍កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្ញុំសូមទាមទារសំណងរដ្ឋប្បវេណីសរុបចំនួន ២.២០០០ (ពីរម៉ឺនពីរពាន់) ដុល្លាអាមេរិក ដោយរួមទាំងកូនរបស់ខ្ញុំទាំងពីរដែលបានស្លាប់ និងប្រពន្ធរបស់ខ្ញុំ និងខ្ញុំផងដែរ។

ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណារិទ្ធ៖ ខ្ញុំឈ្មោះ [redacted] ណារិទ្ធ ត្រូវជាឪពុកឈ្មោះ [redacted] សារ័ត្ន ដែលជាជនរងគ្រោះក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្ញុំសូមទាមទារសំណងជំនួសកូនស្រីរបស់ខ្ញុំចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លាអាមេរិក។

ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភា៖ ខ្ញុំឈ្មោះ [redacted] សុភា ត្រូវជាម្ដាយមីងរបស់ឈ្មោះ [redacted] វណ្ណៈ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅភូមិអូរតាមែង ឃុំ

អន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្លួនសូមទាមទារសំណងជំនួសឈ្មោះ [redacted] វណ្ណៈ ចំនួន ១.៨០០០(មួយម៉ឺនប្រាំបីពាន់)ដុល្លាអាមេរិក។

ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រីនៈ ខ្លួនឈ្មោះ [redacted] រីន ត្រូវជាបងប្រុសបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] រដ្ឋា ដែលជាជនរងគ្រោះក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្លួនសូមទាមទារសំណងជំនួសឈ្មោះ [redacted] រដ្ឋា ចំនួន ៥០០០ (ប្រាំពាន់)ដុល្លាអាមេរិក។

ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដេតៈ ខ្លួនឈ្មោះ [redacted] ដេត ត្រូវជាកូនប្រុសារបស់ឈ្មោះ [redacted] កន ដែលជាជនរងគ្រោះក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្លួនសូមទាមទារ សំណងជំនួសឈ្មោះ [redacted] កន ចំនួន ៨០០០ (ប្រាំបីពាន់)ដុល្លាអាមេរិក។

ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំណាងៈ ខ្លួនឈ្មោះ [redacted] សំណាង ត្រូវជាអ្នកតំណាងឱ្យឈ្មោះ [redacted] យួន ដែលជាជនរងគ្រោះក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្លួនសូមទាមទារសំណងជំនួសឈ្មោះ [redacted] យួន ចំនួន ២៥០០ (ពីរពាន់ប្រាំរយ)ដុល្លាអាមេរិក។

ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចុលៈ ខ្លួនឈ្មោះ [redacted] ចុល ត្រូវជាអ្នកតំណាងឱ្យឈ្មោះ [redacted] ដាន ដែលជាជនរងគ្រោះក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្លួនសូមទាមទារសំណង ជំនួសឈ្មោះ [redacted] ដាន ចំនួន ១០០០ (មួយពាន់)ដុល្លាអាមេរិក។

ជនជាប់ចោទឈ្មោះ [redacted] វិបុល បានឆ្លើយសារភាពថា ខ្លួនឈ្មោះ [redacted] វិបុល ខ្លួនសូមសំណូមពរឱ្យតុលាការជួយឱ្យក្រុមហ៊ុនចូលខ្លួនមកដោះស្រាយសំណងការខូចខាតទាំងស្រុង។ សូមមេត្តាតុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីៈ ខ្លួនជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនវណ្ណៈ និងឈ្មោះ [redacted] ពុទ្ធារី។ ខ្លួនយល់ឃើញថា ការដែលដឹកអ្នកដំណើរឡានោះបានដឹកឥវ៉ាន់ទាំងលើទាំងក្រោមពេញទាំងអស់ ដ៏លការណ៍នេះហើយធ្វើឱ្យឥវ៉ាន់ទាំងនោះបានសង្កត់លើកូនរបស់កូនក្តីខ្លួនស្លាប់ទាំងពីរតែម្តង។ ចំណុចនេះគឺជាការខ្វះចន្លោះ និងធ្វេសប្រហែសរបស់អ្នកបើកបរឡាន ក៏ដូចជាក្រុមហ៊ុនដឹកអ្នកដំណើរទាំងស្រុងតែម្តង។ ខ្លួនសុំទាមទារសំណងចំនួន ២២០០០ (ពីរម៉ឺនពីរពាន់)ដុល្លាអាមេរិក ចំពោះការខូចខាតដែលកូនក្តីរបស់ខ្លួនបានទទួលរង។

*លោកតំណាងអយ្យការ* បានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ថាៈ ក្រោយពីបានស្តាប់ កិច្ចពិភាក្សាដេញដោលយល់ឃើញថា កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅកំណាត់ ផ្លូវលេខ ៦៧B ចន្លោះបង្គោលគីឡូម៉ែត្រលេខ៩៦-៩៧ ស្ថិតនៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ពិតជាមានគ្រោះ



Scanned with CamScanner

ថ្នាក់ចរាចរណ៍ដែលបង្កឡើង ដោយអ្នកបើកបរឈ្មោះ [redacted] វិបុល ពិតប្រាកដមែន។ អំពើនេះជាបទល្មើស បើកបរដោយ ធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរព កាតព្វកិច្ចបណ្តាលឱ្យ មានរបួសដល់អ្នកដទៃ និងបណ្តាលឱ្យស្លាប់អ្នកដទៃ ដែលត្រូវផ្តន្ទាទោសតាមមាត្រាតាមមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ តំណាងអយ្យការប្តឹងសុំឱ្យតុលាការធ្វើការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និង ស្នើសុំឱ្យតុលាការសម្រេចអំពូសំណងរដ្ឋប្បវេណីជូនជនរងគ្រោះតាមព្យសនកម្មដែលទទួលរង។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] វិបុល

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យឯកសារផ្សេងៗក្នុងសំណុំរឿង

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅកំណាត់ ផ្លូវលេខ ៦៧B ចន្លោះបង្គោលគីឡូ ម៉ែត្រលេខ៩៦-៩៧ ស្ថិតនៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ពិតជាមានគ្រោះថ្នាក ចរាចរណ៍ ដែលបង្កឡើង ដោយអ្នកបើកបរឈ្មោះ [redacted] វិបុល ពិតប្រាកដមែន។ អំពើនេះជាបទល្មើស បើកបរដោយ ធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឱ្យមានរបួសដល់អ្នកដទៃ និង បណ្តាល ឱ្យស្លាប់អ្នកដទៃ ដែលត្រូវផ្តន្ទាទោសតាមមាត្រាតាមមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ ផ្លូវគោក។

-ជនជាប់ចោទបានបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ធ្វើឱ្យមានរបួស និងស្លាប់ដល់ អ្នកដទៃ ដែលអំពើនេះបានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយប៉ះពាល់ដល់សុវត្ថិភាពរបស់ អ្នកដំណើរ ជាពិសេសបានល្មើសនឹងច្បាប់រដ្ឋ។

-ជនជាប់ចោទជានីតិជន ដែលមានសមត្ថភាពគ្រប់គ្រាន់អាចទទួលខុសត្រូវព្រហ្មទណ្ឌបាន ពោលគឺជន ជាប់ចោទ មានស្មារតីគ្រប់គ្រាន់ អាចដឹងខុសត្រូវនូវអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត។

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើៈ

ឈ្មោះ អុន វិបុល ភេទប្រុស អាយុ ៦៧ឆ្នាំ

ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឱ្យ មានរបួសដល់អ្នកដទៃ និងបណ្តាលឱ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅកំណាត់ ផ្លូវលេខ ៦៧B ចន្លោះបង្គោល គីឡូម៉ែត្រលេខ៩៦-៩៧ ស្ថិតនៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរ មានជ័យ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ ផ្លូវគោក។

**ហេតុដូច្នេះសាលាដំបូងខេត្តឧត្តរមានជ័យ**

**សម្រេច ៖**

១.ផ្តន្ទាទោសៈ

ឈ្មោះ [redacted] វិបុល ភេទប្រុស អាយុ ២៧ឆ្នាំ(មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ

ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច បណ្តាលឱ្យមានរបួសដល់អ្នកដទៃ និងបណ្តាលឱ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅកំណាត់ ផ្លូវលេខ ៦៧B ចន្លោះបង្គោលគីឡូម៉ែត្រលេខ៩៦-៩៧ ស្ថិតនៅភូមិអូរតាមែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរ មានជ័យ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២.ពិន័យជាប្រាក់លើក្រុមហ៊ុនដឹកអ្នកដំណើរ [redacted] ស៊ុនអ៊ូ ចំនួន ២០.០០០.០០០៖០០ (ម្ភៃលាន) រៀល ដាក់ចូលថវិការរដ្ឋគិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

៣.បង្គាប់ឱ្យក្រុមហ៊ុនដឹកអ្នកដំណើរ [redacted] ស៊ុន អ៊ូ សងសំណងការខូចខាតទៅជនរងគ្រោះរួមមានៈ

៣.១ឈ្មោះ [redacted] ប៊ុនវណ្ណៈ ចំនួន ៥០.០០០.០០០(ហាសិបលាន)រៀល

៣.២ឈ្មោះ [redacted] សារ័ត្ន ចំនួន ២០.០០០.០០០ (ម្ភៃលាន)រៀល

៣.៣.ឈ្មោះ [redacted] វណ្ណ ចំនួន ៣០.០០០.០០០(សាមសិបលាន)រៀល

៣.៤ឈ្មោះ [redacted] រដ្ឋា ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន)រៀល

៣.៥ឈ្មោះ [redacted] កន ចំនួន ២០.០០០.០០០. (ម្ភៃលាន)រៀល

៣.៦ ឈ្មោះ [redacted] យួន ចំនួន ១០.០០០.០០០ (ដប់លាន)រៀល

៣.៧ ឈ្មោះ [redacted] ដាន ចំនួន ៤.០០០.០០០ (បួនលាន)រៀល គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

សាលក្រមនេះជំនុំជម្រះនិងប្រកាសជាសាធារណៈថ្ងៃចន្ទ ១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វិបុល , ដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ទុកសិទ្ធិឱ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជី**
**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជំម្រះ**
**ហត្ថលេខា និងត្រា** [redacted]

---

**បានឃើញ**

ថ្ងៃចន្ទ ១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ខេត្តឧត្តរមានជ័យ,ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០
**ចៅក្រមជំនុំជម្រះ**

[redacted]

**បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃចន្ទ ១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ខេត្តឧត្តរមានជ័យ,ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner